# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

Letter of KKC to the Cambodian prime minister requesting the latter to review and reinvestigate the forcibly defrocked case of His Ven. Tim Sakhorn. 100807
www.khmerkromngo.org

លេខ ០៣៤៧/០៧ ស.ខ.ក.ក.

**គោរពជូន**

**សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ :** សំណើសុំសម្តេចនាយករដ្ឋមន្ត្រីមេត្តាពិនិត្យឡើងវិញករណីចាប់ផ្សឹកព្រះតេជគុណ ទឹម សាខន ព្រះចៅអធិការវត្តភ្នំដិនខាងជើង ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ ។

**យោង :** លិខិតលេខ ៣៩.ស.ជ.ណ កបច ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ របស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានក្រាបបង្គំទូលថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ

តបតាមកម្មវត្ថុ និងយោងខាងលើ ក្នុងនាមអង្គការ សមាគមខ្មែរកម្ពុជាក្រោម ខ្ញុំសូមអនុញ្ញាតជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា :

**ទី១ :** ព្រះតេជគុណ **ទឹម សាខន** កើតនៅភូមិខ្វាគ្របហឹម ឃុំបាជុក ស្រុកស្វាយទង ខេត្តមាត់ជ្រូក (អាងយ៉ាង) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ នៅឆ្នាំ១៩៧៨ ក្នុងពេលដែលកងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយចូលប្រទេសវៀតណាម បានកេណ្ឌប្រជារាស្ត្រខ្មែរជាច្រើននៅខេត្តមាត់ជ្រូក (អាងយ៉ាង) ឲ្យមករស់នៅភូមិភ្នំដិនខាងជើង ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ រហូតដល់សព្វថ្ងៃ ក្នុងនោះក៏មានក្រុមគ្រួសារព្រះតេជគុណ ទឹម សាខន ផងដែរ ។ ការរស់នៅរបស់ក្រុមគ្រួសារព្រះតេជគុណ **ទឹម សាខន** មានលក្ខណៈស្របច្បាប់ជាពលរដ្ឋខ្មែរ ហើយមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ដោយបានផ្តល់សៀវភៅគ្រួសារ និងប័ណ្ណស្នាក់នៅយ៉ាងត្រឹមត្រូវ ។ ព្រះតេជគុណ ទឹម សាខន បានចូលបួសជាសង្ឃនៅក្នុងវត្តបោក្ខណារាម (ភ្នំដិនខាងជើង) រហូតដល់ឆ្នាំ២០០២ ត្រូវបានសម្តេចព្រះសង្ឃរាជ ទេព វង្ស ចេញសញ្ញាប័ត្រតែងតាំងជាព្រះចៅអធិការវត្តភ្នំដិនខាងជើង ។

**ទី២ :** សម្តេចបានលើកឡើងទូលព្រះមហាវីរក្សត្រថា ព្រះតេជគុណ ទឹម សាខន បានយកវត្តអារាមធ្វើជាទីកន្លែងចែកចាយព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលមានខ្លឹមសារឃោសនាញុះញង់ក្នុងគោលបំណងបង្ក ជម្លោះរវាងកម្ពុជា-វៀតណាម ។ ចំណុចនេះ ខ្ញុំសូមជំរាបជូនសម្តេចមេត្តាជ្រាបថា ព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោម មិនមែនចែកចាយតែនៅក្នុងវត្តភ្នំដិនទេ នៅរាជធានីភ្នំពេញក៏មានការចែកចាយលក់ស្មើរគ្រប់តូបលក់កាសែត ប៉ុន្តែពុំឃើញមានការហាមប្រាម ឬព្រមានពីក្រសួងព័ត៌មានឡើយ ។

**ទី៣ :** សម្តេចបានលើកឡើងថា ព្រះតេជគុណ ទឹម សាខន បានបង្កតទង់ ដែលមានទ្រង់ទ្រាយស្រដៀងគ្នាជាមួយសញ្ញាសំគាល់លើព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោម សាងសង់សំណង់រឹងមួយខ្នងជាប់នឹងរបងវត្តខាងក្នុង បំបួសព្រះសង្ឃមួយចំនួន ដោយខុសច្បាប់ ទាក់ទាញព្រះសង្ឃ និងឧបាសិកាមួយចំនួនធំដោយជ្រកក្រោមផ្លាកសហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេសជាដើម ។ ចំណុចនេះ ខ្ញុំសូមជំរាបជូនសម្តេចជ្រាបថា នោះគ្រាន់តែជាសញ្ញាសំគាល់របស់សហព័ន្ធខ្មែរកម្ពុជាក្រោមដែលបានចូលជាសមាជិក UNPO តែប៉ុណ្ណោះ ព្រោះដោយសារប្រជារាស្ត្រខ្មែរកំណើតកម្ពុជាក្រោមភាគច្រើនមានមោទនភាពថា ទឹកដីកម្ពុជាក្រោមត្រូវបាត់បង់ប្រជាជាតិខ្មែរ នៅកម្ពុជាក្រោម ត្រូវអាជ្ញាធរអាណានិគមវៀតណាមធ្វើបាបកាប់សម្លាប់ស្ទើរផុតពូជ តែសំណាងល្អបាន UNPO ទទួលស្គាល់ឲ្យចូលជាសមាជិកពេញសិទ្ធិ ទើបពួកគេយកទង់សញ្ញានោះមកទុកធ្វើជាអនុស្សាវរីយ៍ទៅ ។ រីឯសំណង់នោះគ្រាន់តែជាសំណង់តូចមួយ សំរាប់ធ្វើការិយាល័យសាខាមិត្តសមាគមខ្មែរកម្ពុជាក្រោមតែប៉ុណ្ណោះ ។ ចំណែកការ

ភូមិគ្រឹះលេខ៥៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៩ ៨៩១, ១២ ៨៩១ ៩៩១ / ១០ ៨៨ ៨២.
អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org

បំបួសព្រះសង្ឃខុសច្បាប់ ការទាក់ទាញមនុស្សឲ្យជឿសហព័ន្ធខ្មែរកម្ពុជាក្រោម មិនមែនជាទោស អាបត្តិបារាជិក ក្នុងវិន័យសង្ឃពុទ្ធសាសនានោះទេ ។

**ទី៤ :** សម្តេចបានលើកឡើងថា ព្រះតេជគុណ **ទីម សាខន** បានចូលរួមធ្វើបាតុកម្មចំនួនពីរលើក ប្រឆាំងនឹងមិត្តភាពកម្ពុជា វៀតណាម នោះមិនមែនជាការពិតឡើយ ព្រោះព្រះតេជគុណ **ទីម សាខន** មិនដែលបានចូលរួមធ្វើបាតុកម្មទាំងពីរលើកនោះទេ ។ ចំពោះព្រះសង្ឃដែលរងគ្រោះនៅពេលនោះមិនមែនព្រះសង្ឃ២០អង្គដែលមករារាំង ឬសំរបសំរួលនោះឡើយ គឺព្រះសង្ឃខ្មែរដែលបានដង្ហែក្បួននោះវិញទេ ដែលទទួលការដេញវាយបំបែកហ្វូង និងធ្វើឲ្យព្រះសង្ឃ៤ព្រះអង្គរងរបួស ក្នុងនោះមានមួយអង្គបែកចិញ្ចើមហូរឈាមយ៉ាងដំណំ ។ នេះមានអង្គការសិទ្ធិមនុស្សសហប្រជាជាតិជាសាក្សី ។

**ទី៥ :** សម្តេចបានលើកឡើងអំពីមូលហេតុនៃការចាប់ផ្សឹកព្រះតេជគុណ **ទីម សាខន** ថាបានប្រព្រឹត្តខុសធម៌វិន័យរបស់ព្រះសង្ឃយ៉ាងធ្ងន់ធ្ងរ ។ ចំណុចនេះ ខ្ញុំសូមជំរាបជូនសម្តេចមេត្តាជ្រាបថា បើពិនិត្យរាល់ចំណុច ដែលសម្តេចបានលើកឡើងថាជាកំហុសនោះ ពុំមានចំណុចណាមួយបង្ហាញថាព្រះតេជគុណ **ទីម សាខន** បានប្រព្រឹត្តខុសនឹងធម៌វិន័យក្នុងករណីអាបត្តិបារាជិកដែលត្រូវចាប់ផ្សឹកនោះឡើយ ព្រោះក្នុងព្រះវិន័យព្រះពុទ្ធសាសនាមានតែអាបត្តិបារាជិក៤ប៉ុណ្ណោះទើបអាចចាប់ផ្សឹកភិក្ខុសង្ឃបាន ។ បើមិនដូច្នោះទេ ភិក្ខុសង្ឃអង្គណាមួយ រកលេសឬចោទភិក្ខុសង្ឃដទៃទៀតដោយគ្មានមូល ភិក្ខុសង្ឃអង្គនោះត្រូវអាបត្តិសង្ឃាទិសេស ត្រង់សិក្ខាបទទី០៩-១០ ។

**ទី៦ :** សម្តេចបានលើកឡើងអំពីការឆែកឆេរថា បានរកឃើញភស្តុតាងមួយចំនួនបង្ហាញពីបទល្មើសរបស់ព្រះតេជគុណ **ទីម សាខន** ក្នុងនោះក៏បានពិនិត្យឃើញលិខិតស្នើសុំមួយច្បាប់របស់ព្រះតេជគុណ **ទីម សាខន** ស្នើសុំទៅស្រុកកំណើតវិញ(ប្រទេសវៀតណាម) ។ ចំណុចនេះ ខ្ញុំសូមជំរាបជូនសម្តេចមេត្តាជ្រាបថា បន្ទាប់ពីការចាប់ផ្សឹកព្រះតេជគុណ **ទីម សាខន** នៅវត្តសីហរតនារាម ក្នុងទីរួមខេត្តតាកែវ (សាលាគណខេត្តតាកែវ) នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង ៣ : ៣០ នាទីល្ងាច ស្រាប់តែនៅវេលាម៉ោង ៤ : ៣០ នាទីល្ងាចថ្ងៃដដែលមាន ប៉ូលិស ប៉េអឹម និងអាជ្ញាធរប្រហែល ១០នាក់ ចូលទៅឆែកឆេរក្នុងបន្ទប់ព្រះតេជគុណ **ទីម សាខន** ដោយពុំមានដីកាឆែកឆេរឡើយ ។ ស្អែកឡើងមានការឆែកឆេរម្តងទៀតដឹកនាំដោយលោកព្រះរាជអាជ្ញា ជ័យ សុផល នៅវេលាម៉ោង ១១ ថ្ងៃត្រង់ ។ សាក្សីដែលបានឃើញហេតុការណ៍ និងក្រុមស៊ើបអង្កេតនៃអង្គការសិទ្ធិមនុស្សនានា បានធ្វើការសន្និដ្ឋានថាគម្រោងការនេះហាក់ដូចមានការរៀបចំទុកជាមុន ។ ចំពោះលិខិតស្នើសុំនោះ មិនមែនជាអក្សរសរសេរផ្ទាល់ដៃរបស់ព្រះតេជគុណ **ទីម សាខន** ទេ ហើយពាក្យពេចន៍ក្នុងលិខិតនោះទៀត មិនបានសរសេរត្រឹមត្រូវតាមសង្ឃស័ព្ទឡើយ ។

ដើម្បីបង្ហាញការពិតជូនសម្តេចជ្រាប ខ្ញុំសូមផ្ញើជូនភ្ជាប់មកជាមួយនូវរបាយការណ៍ និងភស្តុតាងដែលបានប្រមូលបានពីការដែលបានស៊ើបអង្កេតជូនសម្តេចពិនិត្យតាមការគួរ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមសម្តេចនាយករដ្ឋមន្ត្រីមេត្តាពិចារណា ករណីព្រះតេជគុណ ទីម សាខន ឡើងវិញដើម្បីស្វែងរកការពិត និងផ្តល់យុត្តិធម៌ប្រគេនព្រះអង្គ ដោយអនុគ្រោះ ។

សូមសម្តេចនាយករដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

សេចក្តីពុំគួរ សូមសម្តេចនាយករដ្ឋមន្ត្រីមេត្តាអនុគ្រោះ ។

*រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧*

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**

**សមាជិកព្រឹទ្ធសភា**

**ចម្លងជូន និង ថ្វាយ :**

_ ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

_ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

_ ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា
"ដើម្បីទទួលថ្វាយ និងជូនជ្រាប"

_ ឯកសារ-កាលប្បវត្តិ

Letter of KKC to the Cambodian prime minister requesting the latter to review and reinvestigate the forcibly defrocked case of His Ven. Tim Sakhorn. 100807
www.khmerkromngo.org